# តើអ្នកគួរតែធ្វើតេស្តរកមើលរោគរលាកថ្លើមប្រភេទ B ដែរទេ?



- រោគរលាកថ្លើមប្រភេទ B គឺជាវីរុសដែលវាយប្រហារថ្លើម និងអាចបង្កជាមហារីកថ្លើម។
- មនុស្សជាច្រើនមិនដឹងខ្លួនថាបានឆ្លងមេរោគ ដោយសារពួកគេមិនមានអារម្មណ៍ ឬមើលទៅដូចជាមានជំងឺទេ ប៉ុន្តែពួកគេអាចចម្លងមេរោគនេះទៅអ្នកដទៃបាន។
- មានវ៉ាក់សាំងដែលមានប្រសិទ្ធភាព និងសុវត្ថិភាព ដែលអាចបង្ការរោគរលាកថ្លើមប្រភេទ B។

## រោគរលាកថ្លើមប្រភេទ B ចម្លងតាមរយៈ៖

- មនុស្សមានផ្ទៃពោះទៅទារកអំឡុងពេលសម្រាលកូន
- ការប៉ះពាល់ផ្លូវភេទ
- ការប៉ះពាល់ឈាមរបស់មនុស្សដែលបានឆ្លងរោគ
- ការប្រើថ្លៃឡាម ច្រាសដុសធ្មេញ ឬកន្ត្រៃកាត់ក្រចករួមគ្នា

## រោគរលាកថ្លើមប្រភេទ B មិនចម្លងតាមរយៈ៖

- ការប្រើសម្ភារៈញ៉ាំអាហារ ឬញ៉ាំអាហាររួមគ្នា
- ការអោប ថើប ឬកាន់ដៃគ្នា

## តើនរណាខ្លះគួរធ្វើតេស្ត?

- មនុស្សមានផ្ទៃពោះ
- មនុស្សដែលរស់នៅជាមួយនរណាម្នាក់ដែលមានផ្ទុករោគរលាកថ្លើមប្រភេទ B
- មនុស្សដែលបានកើតក្នុងតំបន់ដែលមានការឆ្លងរោគរលាកថ្លើមប្រភេទBជាញឹកញាប់ដូចជានៅទ្វីបអាហ្វ្រិកឬអាស៊ីជាដើមឬមានឪពុកម្តាយដែលបានកើតនៅតំបន់ទាំងនោះ។
- មនុស្សដែលមានកត្តាហានិភ័យមួយចំនួន

សម្រាប់ព័ត៌មានបន្ថែម៖

**www.cdc.gov/hepatitis/hbv/**
**doh.wa.gov/hepbhub**

Hep B Hub
doh.wa.gov/hepbhub

Washington State Department of Health
DOH 420-408 May 2022 Khmer

ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទូរសព្ទទៅលេខ 1-800-525-0127។ អតិថិជនស្ដាប់មិនឮ ឬស្ដាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ civil.rights@doh.wa.gov។

បានកែសម្រួលដោយមានការអនុញ្ញាតពី Minnesota Department of Health (ក្រសួងសុខាភិបាលនៃរដ្ឋមីណេសូតា)